**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល**
លេខៈ ០៦៣/២២ អអរ

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ"

ព្រឹកថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«វឌ្ឍនភាពមូលដ្ឋានឃុំ សង្កាត់ និងទិសដៅការងារបន្ត របស់រដ្ឋបាលខេត្តបន្ទាយមានជ័យ»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ខេង ស៊ុម ប្រធានក្រុមប្រឹក្សាខេត្ត**
- **លោក ខាំ សរ ចៅសង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងបំផុស និងបង្ហាញជាសាធារណៈ នូវយន្តការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ជាប្រវត្តិសាស្ត្ររបស់កម្ពុជា និងផ្សព្វផ្សាយពីសមិទ្ធផល ដែលថ្នាក់មូលដ្ឋានខិតខំប្រឹងប្រែងបំពេញការងារសម្រេចបាន ក្នុងកិច្ចរក្សាបាននូវការជឿទុកចិត្ត ចូលរួម និងគាំទ្រពីប្រជាពលរដ្ឋ តាមយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។

### I. សេចក្តីផ្តើម

ខេត្តបន្ទាយមានជ័យ មានផ្ទៃដីសរុប ៦.៦៧៩គីឡូម៉ែត្រការ៉េ ចែកចេញជាក្រុង២ ស្រុក៧ ឃុំ៥៥ សង្កាត់១២ ភូមិទទួលស្គាល់៦៥៩ភូមិ មាន១៩៦.៤០០គ្រួសារ ស្មើនឹងប្រជាជន ៧៩៤.២៤៥នាក់ ក្នុងនោះស្រី ៤០៤.៥៩៥នាក់ មុខរបរសំខាន់របស់ប្រជាពលរដ្ឋ ៨៥%ជាកសិករ ១០%ជាអាជីវករ ពាណិជ្ជករ និង៥% ប្រកបរមុខរបរផ្សេងៗ ដោយអត្រានៃភាពក្រីក្រទូទាំងខេត្តត្រូវបានកាត់បន្ថយជាបន្តបន្ទាប់ ពី១៧,៥% ក្នុងឆ្នាំ២០១៤ មកនៅត្រឹម១២,៨% ក្នុងឆ្នាំ២០១៧ និងមកនៅត្រឹម១៤,៦១%ក្នុងឆ្នាំ២០២០ (ដោយសារបរិបទនៃជំងឺកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ចខេត្តធ្លាក់ចុះប្រមាណ១,៨១%)។

## II. វឌ្ឍនភាពការងារសំខាន់ៗ

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្តបន្ទាយមានជ័យ បានអនុវត្តតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ខ្លួន តាមរយៈអង្គប្រជុំក្នុងការចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីជានាលើការផ្តល់សេវា និងការអភិវឌ្ឍជូនប្រជាពលរដ្ឋ ប្រកបដោយគុណភាព ប្រសិទ្ធភាព ដោយឈរលើគោលការណ៍អភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្នុងការបំពេញមុខងារ ភារកិច្ច ដែលរាជរដ្ឋាភិបាល បានប្រគល់ និងបានធ្វើប្រតិភូកម្មជូនតាមច្បាប់គតិយុត្ត។

ក្រុមប្រឹក្សាខេត្ត បានធ្វើសេចក្តីសម្រេច ដីកា វិធានការ គោលការណ៍ គោលនយោបាយ ផែនការអភិវឌ្ឍ ៥ឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកាប្រចាំឆ្នាំ និងការដោះស្រាយតម្រូវការជាក់លាក់បន្ទាន់សំដៅជំរុញ កសាង និងអភិវឌ្ឍខេត្ត ធ្វើឱ្យខេត្តបន្ទាយមានជ័យ មានការរីកចម្រើនលើគ្រប់វិស័យ។

### ❖ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ

វឌ្ឍនភាពសំខាន់ៗ ដែលក្រុមប្រឹក្សាសង្កាត់សម្រេចបានរួមមាន៖

- បានកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវបេតុង ប្រព័ន្ធលូរំដោះទឹក ជួសជុលផ្លូវក្រាលគ្រួស និងស្ពារប្រឡាយទឹកនៅតាមបណ្តាភូមិ
- បានផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋរួមមាន៖ បានចុះសំបុត្រកំណើត សំបុត្របញ្ជាក់កំណើត សំបុត្រមរណភាព សំបុត្រអាពាហ៍ពិពាហ៍សរុប ចំនួន៦៩៥។
- បានគាំទ្រឧបត្ថម្ភស្ត្រីក្រីក្រសម្រាលកូននៅមណ្ឌលសុខភាពចំនួន ៨០គ្រួសារ និងបានចុះប្រជុំផ្សព្វផ្សាយដល់មូលដ្ឋាន ស្តីពីការថែទាំសុខភាពមាតានិងទារក
- បានចុះផ្សព្វផ្សាយដល់មូលដ្ឋាន ដើម្បីឱ្យមានការយល់ដឹងកាន់តែច្បាស់ និងដើម្បីការពារសុវត្ថិភាពប្រជាពលរដ្ឋរបស់យើងគ្រប់គ្នា ដោយបានពង្រឹងកម្លាំងប្រជាការពារតាមភូមិ និងបានសហការជាមួយនគរបាលប៉ុស្តិ៍រដ្ឋបាលសង្កាត់ជាប្រចាំ
- បានចុះធ្វើវេទិការសាធារណៈ ភូមិ-ឃុំមានសុវត្ថិភាព ផ្សព្វផ្សាយវិធានការទប់ស្កាត់ជំងឺកូវីដ-១៩ តាមភូមិ វត្តអារាម និងពីធីបុណ្យទាន ផ្សេងៗ និងទទួលយកនូវសំណូមពរឆ្លើយតបដោះស្រាយជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា។

## III. ទិសដៅការងារបន្ត

### ❖ ក្រុមប្រឹក្សាខេត្ត

ក្រុមប្រឹក្សាខេត្ត បានដាក់ចេញនូវទិសដៅការងារចាំបាច់មួយចំនួនដូច ខាងក្រោម៖

- បន្តខិតខំអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ស្តីពីការផ្ទេរអំណាចឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យមានប្រសិទ្ធភាព ពិសេសពង្រឹងរដ្ឋបាលឯកភាពក្រុង ស្រុក សំដៅបង្កើតសេវាឱ្យកាន់តែជិតប្រជាពលរដ្ឋ និងមានប្រសិទ្ធភាព
- បន្តរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្ត និងរៀបចំផែនការចុះគាំទ្រនៅមូលដ្ឋានដើម្បីប្រមូលតម្រូវការជាក់ស្តែងរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តនូវមុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- បន្តជំរុញ និងគាំទ្រការអនុវត្តក្របខណ្ឌការងារគណនេយ្យភាពសង្គម និងយន្តការច្រកចេញចូលតែមួយ
- បន្តពង្រឹង និងគាំទ្រដល់យន្តការសម្រុះសម្រួល និងដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ តាមរយៈការិយាល័យ ប្រជាពលរដ្ឋខេត្ត
- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំក្នុងការអនុវត្តផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល ពិសេសតាមដាន ត្រួតពិនិត្យ និងវាយតម្លៃជាប្រចាំលើការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់
- បន្តជំរុញការអនុវត្តនូវគោលការណ៍រដ្ឋបាលឯកភាព និងគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាពក្នុងន័យជានាសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋឱ្យបានល្អប្រសើរ
- បន្តចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។

### ❖ សង្កាត់ទឹកថ្លា ក្រុងសិរីសោភ័ណ

- បន្តការផ្តល់សេវារដ្ឋបាល និងចំណេះដឹងផ្នែកច្បាប់ ជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា
- បន្តការអភិវឌ្ឍ និងកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់នៅក្នុងសង្កាត់ ឱ្យមានការរីកចម្រើន ដើម្បីឱ្យប្រជាពលរដ្ឋងាយស្រួលនៅក្នុងការធ្វើដំណើរទៅមក។
- បន្តការជំរុញ និងផ្សព្វផ្សាយការងារកសិកម្មនិងបន្លែគ្រប់មុខឱ្យបានទិន្នផលខ្ពស់
- បន្តការជួសជុលប្រព័ន្ធធារាសាស្ត្រ ជួសជុលទំនប់ ស្ពានប្រឡាយ សំណង់ទ្វារទឹកនានា
- បន្តពង្រឹងផ្សព្វផ្សាយគោលនយោបាយភូមិឃុំមានសុវត្ថិភាព ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយ និងសុវត្ថិភាពសង្គមឱ្យកាន់តែបានល្អប្រសើរដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមការរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានសង្កាត់។
- ខិតខំគៀងគរដៃគូ អ្នកវិនិយោគ និងសប្បុរសជនដើម្បីចូលរួមអភិវឌ្ឍន៍នៅក្នុងមូលដ្ឋាន
- បន្តផ្សព្វផ្សាយពីវិធានការ ការពារ ទប់ស្កាត់ និងការប្រយុទ្ធប្រឆាំងនិងការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ នៅក្នុងមូលដ្ឋានសង្កាត់ ។

## IV. សម្គាល់

- រដ្ឋបាលខេត្តបន្ទាយមានជ័យ បានដាក់ចេញនូវគោលការណ៍បង្កើតការិយាល័យច្រកចេញចូលតែមួយ នៅគ្រប់ក្រុង-ស្រុក ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព។

- មកទល់ពេលបច្ចុប្បន្ននេះ ប្រជាពលរដ្ឋនៅក្នុងខេត្តបន្ទាយមានជ័យមានចំនួន ៥៣.៣% មានទឹកប្រើប្រាស់គ្រប់គ្រាន់ ក្នុងនោះ មានស្ថានីយ៍ចែកចាយទឹកចំនួន ៦២ស្ថានីយ៍ អណ្តូងស្នប់ចំនួន ៣,២៣១អណ្តូង, អណ្តូងលូ១,៨០១, អណ្តូងចម្រុះ២,៧៦៦, ស្រះសហគមន៍មានចំនួន ១,១៨៣។ រដ្ឋបាលខេត្ត និងមន្ទីរជំនាញ ខិតខំជម្រុញដល់ការអភិវឌ្ឍទឹកស្អាត ឱ្យស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល គឺនៅឆ្នាំ២០២៥-២០៣០ ប្រជាពលរដ្ឋទាំងអស់ នឹងមានទឹកស្អាតប្រើប្រាស់គ្រប់ៗគ្នា។៕

ថ្ងៃអង្គារ ៧កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២២